ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌

លេខ: ៩៤ កយ.ប្រក/០៩

# ប្រកាស

# ស្តីពី

# នីតិវិធីនៃការផ្ញើទៅតុលាការ

*******

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនៃការប្រព្រឹត្តទៅ នៃគណៈ រដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញក្រឹត្យលេខ ០៦.ក្រ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- យោងតាមការចាំបាច់ក្នុងការអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណី



ផ្លូវសម្តេចសុធារស. ខ័ណ្ឌដូនពេញ. ក្រុងភ្នំពេញ ទូរស័ព្ទ : 023 216 322 , 023 212 693

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-** គោលបំណង

ប្រកាសនេះបញ្ញត្តអំពីនីតិវិធីនៃការផ្ញើប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន នៅតុលាការ ដោយផ្អែកលើក្រមនីតិវិធីរដ្ឋប្បវេណី ។

**ប្រការ ២.-** មន្ត្រីទទួលបន្ទុកកិច្ចការផ្ញើ

កិច្ចការផ្ញើនៅតុលាការ ត្រូវបំពេញដោយក្រឡាបញ្ជីដែលត្រូវបានចាត់តាំងដោយប្រធានតុលាការនៃតុលាការដែលត្រូវទទួលការផ្ញើនោះ ។

**ប្រការ ៣.-** ការចាត់ចែងរបស់ក្រឡាបញ្ជីចំពោះកិច្ចការផ្ញើ

១-ការចាត់ចែងរបស់ក្រឡាបញ្ជីទាក់ទងនឹងកិច្ចការផ្ញើ នឹងមានអានុភាព បន្ទាប់ពីបានជូនដំណឹងតាមរបៀបដែលអាចចាត់ទុកថាសមរម្យ ។

២-ពាក្យសុំតវ៉ាអំពីការចាត់ចែងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវដាក់ជាលាយលក្ខណ៍អក្សរ ទៅតុលាការដែលក្រឡាបញ្ជីដែលបានធ្វើការចាត់ចែងនោះស្ថិតនៅក្រោម ក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ ក្រោយពីបានទទួលដំណឹងនោះ ។

៣-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

៤-ចំពោះដីកាសម្រេចអំពីពាក្យសុំតវ៉ាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៥-ចំពោះបណ្តឹងជំទាស់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ ត្រូវអនុលោមទៅតាមបណ្តឹងជំទាស់ដែលបានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ។

**ប្រការ ៤.-** សមត្ថកិច្ចលើការផ្ញើសម្រាប់ជាប្រាតិភោគលើបណ្តឹង

ការផ្ញើប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន នៅតុលាការ ដែលជាវិធីដាក់ប្រាតិភោគ ដោយយោងតាមបញ្ញត្តិពីគន្ថីទី ១ (បទប្បញ្ញត្តិទូទៅ) ដល់គន្ថីទី ៥ (នីតិវិធីដាស់តឿន) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវធ្វើឡើងនៅតុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគនោះ ។

**ប្រការ ៥.-** ការប្រគល់នូវច្បាប់ដើមនៃឯកសារភ្ជាប់

១-ចំពោះឯកសារដែលភ្ជាប់ជាមួយនឹងលិខិតពាក្យសុំ និង លិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ អ្នកដាក់លិខិតនោះអាចទាមទារឱ្យប្រគល់ នៅពេលដាក់លិខិតនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តចំពោះលិខិតបញ្ជាក់សិទ្ធិអំណាចរបស់អ្នកតំណាងដែលច្បាប់បានកំណត់ និង អ្នកតំណាងដោយអាណត្តិ ។

២-ដើម្បីទាមទារឱ្យប្រគល់ឯកសារភ្ជាប់ អ្នកដាក់លិខិតពាក្យសុំ ឬ លិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ត្រូវភ្ជាប់ជាមួយនឹងលិខិតនោះ នូវឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ថា ការសរសេរនៅក្នុងឯកសារនោះ គ្មានភាពខុសពីច្បាប់ដើម ។

៣-ក្នុងករណីដែលប្រគល់នូវច្បាប់ដើមនៃឯកសារភ្ជាប់ ក្រឡាបញ្ជីត្រូវឱ្យអ្នកទទួលការប្រគល់ សរសេរនៅក្នុងឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នូវការណ៍ដែលខ្លួន បានទទួលការប្រគល់ឯកសារនោះ និង ចុះហត្ថលេខា ។

## ជំពូកទី ២
## នីតិវិធីផ្ញើវត្ថុដែលជាកម្មវត្ថុនៃការផ្ញើ

**ប្រការ ៦.-** ពាក្យសុំផ្ញើ

១-អ្នកដាក់ពាក្យសុំផ្ញើ ត្រូវដាក់ទៅក្រឡាបញ្ជី នូវលិខិតពាក្យសុំផ្ញើមួយច្បាប់សម្រាប់អ្នកផ្ញើ និង មួយច្បាប់សម្រាប់តុលាការ តាមទម្រង់ពីលេខ ១ ដល់លេខ ៦ នៃឧបសម្ព័ន្ធ ទៅតាមប្រភេទនៃការផ្ញើ ដោយភ្ជាប់ជាមួយនឹងវត្ថុដែលជាកម្មវត្ថុនៃ

ការផ្ញើ ។

២-លិខិតពាក្យសុំផ្ញើដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសរសេរចូលនូវចំណុចដូចខាងក្រោម ហើយត្រូវមានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់អ្នកផ្ញើ ឬ អ្នកតំណាងនីតិបុគ្គល (ក្នុងករណីដែលអ្នកផ្ញើជានីតិបុគ្គល) ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិរបស់អ្នកផ្ញើ :

ក-ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត និង អាសយដ្ឋានរបស់អ្នកផ្ញើ ។ ប្រសិនបើអ្នកផ្ញើជានីតិបុគ្គល គឺ នាមករណ៍ ទីតាំងនៃទីស្នាក់ការជាចម្បង និង ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គលនោះ ។

ខ-ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ ប្រសិនបើការផ្ញើត្រូវបានធ្វើឡើងដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ ។

គ-ចំនួនទឹកប្រាក់ផ្ញើ ឬ ប្រសិនបើផ្ញើឧបករណ៍អាចជួញដូរបាន គឺ ឈ្មោះនៃឧបករណ៍នោះ ចំនួនទឹកប្រាក់សរុប ចំនួនទឹកប្រាក់ក្នុងមួយសន្លឹក (ចំពោះឧបករណ៍អាចជួញដូរបានដែលគ្មានសរសេរចំនួនទឹកប្រាក់ទេ ត្រូវសរសេរការណ៍នោះ) លេខស៊េរី លេខរៀង ចំនួនសន្លឹក និង ចំណុចផ្សេងទៀតដែលសម្គាល់អត្តសញ្ញាណនៃឧបករណ៍នោះ ។

ឃ-អង្គហេតុដែលជាមូលហេតុនៃការផ្ញើ ។

ង-បញ្ញត្តិច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងដែលតម្រូវ ឬ អនុញ្ញាតឱ្យផ្ញើ ។

ច-ប្រសិនបើអាចកំណត់បញ្ជាក់អំពីអ្នកដែលអាចទាមទារឱ្យប្រគល់ឱ្យនូវប្រាក់ ឬ ឧបករណ៍អាចជួញដូរបានដែលត្រូវបានផ្ញើ (តទៅហៅថា "អ្នកមានសិទ្ធិទទួលពីការផ្ញើ") គឺ ឈ្មោះ និង អាសយដ្ឋានរបស់អ្នកមានសិទ្ធិទទួលពីការផ្ញើ ហើយប្រសិនបើជាអ្នកមានសិទ្ធិទទួលពីការផ្ញើជានីតិបុគ្គល គឺ នាមករណ៍ ទីតាំងនៃទីស្នាក់ការជាចម្បង និង ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គលនោះ ។

ឆ-ឈ្មោះតុលាការដែលចាត់ការនីតិវិធីនៃការសម្រេចសេចក្តីដែលពាក់

ព័ន្ធនឹងការធ្វើ និង លេខសំណុំរឿង ។

ជ-ឈ្មោះតុលាការដែលត្រូវបានដាក់ពាក្យសុំធ្វើ ។

ឈ-ថ្ងៃ ខែ ឆ្នាំ ដាក់ពាក្យសុំធ្វើ ។

**ប្រការ ៧.-** ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងពាក្យសុំធ្វើ

១-ប្រសិនបើនីតិបុគ្គលមានបំណងធ្វើ នីតិបុគ្គលនោះត្រូវភ្ជាប់ជាមួយនឹងលិខិតពាក្យសុំធ្វើ នូវលិខិតបញ្ជាក់លក្ខណសម្បត្តិរបស់អ្នកតំណាងនៃនីតិបុគ្គលនោះ ។

២-ប្រសិនបើការធ្វើត្រូវបានធ្វើឡើងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ ត្រូវភ្ជាប់ជាមួយនឹងលិខិតពាក្យសុំធ្វើ នូវលិខិតបញ្ជាក់សិទ្ធិអំណាចរបស់អ្នកតំណាងនោះ ។

**ប្រការ ៨.-** ការធ្វើឧបករណ៍អាចជួញដូរបានដែលមានកំណត់ឈ្មោះ

បុគ្គលដែលមានបំណងធ្វើឧបករណ៍អាចជួញដូរបានដែលមានកំណត់ឈ្មោះត្រូវធ្វើបិដ្ឋិលេខន៍ (កាខ្នង) លើឧបករណ៍នោះ ឬ វិធានការផ្សេងទៀត ដើម្បីឱ្យអ្នកដែលទទួលការប្រគល់ឱ្យនូវឧបករណ៍អាចជួញដូរបានដែលមានកំណត់ឈ្មោះនោះអាចធ្វើលទ្ធកម្មសិទ្ធិបានភ្លាមៗ ។

**ប្រការ ៩.-** ការធ្វើដើម្បីការប្តូរប្រាតិភោគ

១-ការប្តូរវត្ថុធ្វើដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៧១ (វិធីដាក់ប្រាតិភោគ និង ការប្តូរប្រាតិភោគ) នៃក្រមនីតិវិធីរដ្ឋប្បវេណី (រួមបញ្ចូលទាំងករណីដែលបញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នា ដោយយោងតាមមាត្រា ៣៧៧ (ការដាក់ប្រាតិភោគ) កថាខណ្ឌទី ៤ នៃមាត្រា ៤៦១ (ការលុបចោលនីតិវិធីលក់ដោយបង្ខំ ដោយដាក់ប្រាក់ធានា) និង មាត្រា ៥៣៦ (ការផ្តល់នូវប្រាតិភោគ) នៃក្រមនីតិវិធីរដ្ឋប្បវេណី) ត្រូវអនុវត្តតាមវិធីដែលបុគ្គលដែលត្រូវផ្តល់ប្រាតិភោគ ធ្វើការធ្វើជាថ្មីដោយផ្អែកលើដីកាសម្រេចបង្គាប់ឱ្យប្តូរវត្ថុប្រាតិភោគរបស់តុលាការ ហើយក្រោយមក ទទួលការប្រគល់នូវវត្ថុដែលត្រូវបានធ្វើពេលមុន ។

២-នៅពេលធ្វើការផ្ញើដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បុគ្គលដែលធ្វើការផ្ញើ ត្រូវបញ្ជាក់ថា គោលបំណងនៃការផ្ញើនេះគឺដើម្បីប្តូរប្រាតិភោគ ហើយត្រូវបញ្ជាក់អំពីខ្លឹមសារនៃដីកាសម្រេចបង្គាប់ឱ្យប្តូរប្រាតិភោគរបស់តុលាការ និង ចំណុចដែលអាចកំណត់នូវអត្តសញ្ញាណនៃវត្ថុដែលកំពុងត្រូវបានផ្ញើ ។

**ប្រការ ១០.-** នីតិវិធីទទួលពាក្យសុំផ្ញើ

ប្រសិនបើយល់ឃើញថា ត្រូវទទួលពាក្យសុំផ្ញើ ក្រឡាបញ្ជីត្រូវចុះ ក្នុងលិខិតពាក្យសុំផ្ញើសម្រាប់អ្នកផ្ញើ នូវការណ៍ដែលទទួលពាក្យសុំផ្ញើ ការណ៍ដែលទទួលវត្ថុផ្ញើ និង លេខផ្ញើ រួចចុះហត្ថលេខា ហើយត្រូវប្រគល់លិខិតពាក្យសុំផ្ញើសម្រាប់អ្នកផ្ញើនោះទៅឱ្យអ្នកផ្ញើ ។

**ប្រការ ១១.-** បញ្ញត្តិពិសេសអំពីការទទួលប្រាក់ផ្ញើ

១-ចំពោះការផ្ញើប្រាក់ ប្រសិនបើមានការស្នើសុំរបស់បុគ្គលដែលមានបំណងផ្ញើ ក្រឡាបញ្ជីអាចទទួលការផ្ទេរប្រាក់ផ្ញើនៅក្នុងគណនីរបស់ក្រឡាបញ្ជី (តុលាការ) បាន ជំនួសការដាក់ប្រាក់ ដោយយោងតាមបញ្ញត្តិនៃប្រការ ៦ (ពាក្យសុំផ្ញើ) ។ ក្នុងករណីនេះ ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៦ នោះក៏ដោយ ក៏បុគ្គលដែលមានបំណងផ្ញើប្រាក់ ត្រូវដាក់ទៅក្រឡាបញ្ជីនូវលិខិតពាក្យសុំផ្ញើមួយច្បាប់សម្រាប់អ្នកផ្ញើ និង មួយច្បាប់សម្រាប់តុលាការ តាមទម្រង់ពីលេខ ៧ ដល់លេខ ១០ នៃឧបសម្ព័ន្ធ ទៅតាមប្រភេទនៃការផ្ញើដែរ ។

២-ក្នុងករណីដែលមានការស្នើសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថា ត្រូវទទួលការផ្ញើដែលបានកំណត់នៅក្នុងកថាខណ្ឌដដែលនេះ ក្រឡាបញ្ជីត្រូវចុះ ក្នុងលិខិតពាក្យសុំផ្ញើសម្រាប់អ្នកផ្ញើ នូវការណ៍ដែលទទួលពាក្យសុំផ្ញើ លេខផ្ញើ និង កាលបរិច្ឆេទនៃការទទួលផ្ញើ រួចចុះហត្ថលេខា ហើយត្រូវចុះ ក្នុងលិខិតពាក្យសុំផ្ញើសម្រាប់តុលាការ នូវកាលបរិច្ឆេទនៃការទទួលផ្ញើ និង ចុះហត្ថលេខា ហើយត្រូវសរសេរនូវកាលបរិច្ឆេទកំណត់សម្រាប់ការផ្ទេរប្រាក់ ។

ក្រឡាបញ្ជីត្រូវរក្សាទុកនូវលិខិតពាក្យសុំផ្ញើទាំងពីរនោះ ។

៣-នៅពេលដែលក្រឡាបញ្ជីទទួលការផ្ញើ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ក្រឡាបញ្ជីត្រូវជូនដំណឹងទៅអ្នកផ្ញើអំពីការណ៍ដែលត្រូវផ្ទេរប្រាក់ផ្ញើមកគណនី រហូតដល់កាលបរិច្ឆេទកំណត់សម្រាប់ការផ្ទេរប្រាក់ និង ការណ៍ដែលការសម្រេចទទួលការផ្ញើ ត្រូវបាត់បង់អានុភាព ប្រសិនបើមិនបានផ្ទេរប្រាក់ផ្ញើរហូតដល់កាលបរិច្ឆេទដែលបានកំណត់នោះ ដោយប្រគល់លិខិតជូនដំណឹងអំពីការសម្រេចទទួលការផ្ញើ តាមទម្រង់លេខ ១១ ហើយត្រូវចុះ នៅក្នុងលិខិតស្នើសុំផ្ទេរប្រាក់ តាមទម្រង់លេខ ១២ នូវនាមករណ៍នៃស្ថាប័នហិរញ្ញវត្ថុ នៅចំណុច "ស្ថាប័នហិរញ្ញវត្ថុ" លេខគណនី និង ឈ្មោះរបស់ម្ចាស់គណនី នៅចំណុច "អ្នកទទួលការផ្ទេរប្រាក់" និង ចំនួនទឹកប្រាក់ផ្ញើ នៅចំណុច "ចំនួនទឹកប្រាក់" រួចត្រូវប្រគល់ លិខិតស្នើសុំផ្ទេរប្រាក់នោះ ទៅឱ្យអ្នកផ្ញើ ។

៤-កាលបរិច្ឆេទកំណត់សម្រាប់ការផ្ទេរប្រាក់ ត្រូវកំណត់ជាថ្ងៃដែលមានអំឡុងពេលមិនតិចជាង ១ (មួយ) សប្តាហ៍ គិតចាប់ពីថ្ងៃទទួលការផ្ញើ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកាលបរិច្ឆេទកំណត់សម្រាប់ការផ្ទេរប្រាក់ ត្រូវបានកំណត់នៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្ត ឬ សេចក្តីសម្រេចដែលបង្គាប់ឱ្យផ្ញើ ។

៥-ប្រសិនបើអ្នកផ្ញើមិនផ្ទេរប្រាក់ផ្ញើរហូតដល់កាលបរិច្ឆេទដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ការសម្រេចទទួលការផ្ញើត្រូវបាត់បង់អានុភាព ។

៦-ប្រសិនបើអ្នកផ្ញើផ្ទេរប្រាក់ផ្ញើរហូតដល់កាលបរិច្ឆេទដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ក្រឡាបញ្ជីត្រូវចុះ ក្នុងលិខិតពាក្យសុំផ្ញើសម្រាប់អ្នកផ្ញើនូវការណ៍ដែលទទួលប្រាក់ផ្ញើ រួចចុះហត្ថលេខា ហើយប្រគល់លិខិតពាក្យសុំសម្រាប់អ្នកផ្ញើនោះទៅឱ្យអ្នកផ្ញើ ។

**ប្រការ ១២**.- ការលើកចោលនូវពាក្យសុំផ្ញើ

ប្រសិនបើយល់ឃើញថា មិនត្រូវទទួលពាក្យសុំផ្ញើទេ ក្រឡាបញ្ជីត្រូវធ្វើលិខិត

លើកចោលពាក្យសុំ ហើយប្រគល់លិខិតនោះឱ្យអ្នកផ្ញើ ។

## ជំពូកទី ៣
## នីតិវិធីប្រគល់នូវវត្ថុផ្ញើ

**ប្រការ ១៣.-** ការប្រគល់ឱ្យនូវវត្ថុផ្ញើ

ជនដែលទាមទារឱ្យប្រគល់ឱ្យនូវវត្ថុផ្ញើ ត្រូវបញ្ជាក់ពីសិទ្ធិទាមទារឱ្យប្រគល់ឱ្យរបស់ខ្លួននោះ ដោយអនុលោមតាមបញ្ញត្តិនៃប្រកាសនេះ ។

**ប្រការ ១៤.-** ការប្រគល់វិញនូវវត្ថុផ្ញើ

អ្នកផ្ញើអាចទាមទារឱ្យប្រគល់វិញនូវវត្ថុផ្ញើ ដោយអនុលោមតាមបញ្ញត្តិនៃប្រកាសនេះបាន តែក្នុងករណីដែលអ្នកផ្ញើនោះបញ្ជាក់នូវចំណុចណាមួយ ក្នុងចំណោមចំណុចខាងក្រោម :

ក-ការផ្ញើត្រូវបានផ្ញើដោយការភាន់ច្រឡំ ។

ខ-មូលហេតុនៃការផ្ញើបានរលត់ ។

**ប្រការ ១៥.-** ការទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ

១-ជនដែលទាមទារឱ្យប្រគល់ឱ្យ ឬ ឱ្យប្រគល់វិញនូវវត្ថុផ្ញើ ត្រូវដាក់ទៅក្រឡាបញ្ជី នូវលិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ តាមទម្រង់លេខ ១៣ ឬ លេខ ១៤ នៃឧបសម្ព័ន្ធ ទៅតាមប្រភេទនៃវត្ថុផ្ញើ ។

២-លិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ត្រូវសរសេរនូវចំណុចខាងក្រោមនេះ ហើយត្រូវមានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់អ្នកទាមទារ ឬ អ្នកតំណាងនីតិបុគ្គល (ក្នុងករណីដែលអ្នកទាមទារជានីតិបុគ្គល) ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិរបស់អ្នកទាមទារ :

ក-លេខបញ្ញើ ។

ខ-ចំនួននៃប្រាក់ផ្ញើដែលទាមទារឱ្យប្រគល់ ឬ ប្រសិនបើទាមទារឱ្យ

ប្រគល់នូវឧបករណ៍អាចផ្ទេរឲ្យផ្លូវបាន គឺ ឈ្មោះ ចំនួនទឹកប្រាក់សរុប ចំនួនទឹកប្រាក់មួយសន្លឹក (ចំពោះឧបករណ៍អាចផ្ទេរញផ្លូវបានដែលគ្មានសរសេរចំនួនទឹកប្រាក់ទេ ត្រូវសរសេរការណ៍នោះ) លេខស៊េរី លេខរៀង ចំនួនសន្លឹក និង ចំណុចផ្សេងទៀតដែលសម្គាល់អត្តសញ្ញាណនៃឧបករណ៍នោះ ។

គ-មូលហេតុនៃការទាមទារឱ្យប្រគល់ ។

ឃ-ប្រភេទនៃការទាមទារឱ្យប្រគល់ (ជាការទាមទារឱ្យប្រគល់ឱ្យ ឬ ជាការទាមទារឱ្យប្រគល់វិញ) ។

ង-ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត និង អាសយដ្ឋានរបស់អ្នកទាមទារ ហើយប្រសិនបើអ្នកទាមទារជានីតិបុគ្គល គឺ នាមករណ៍ ទីតាំងនៃទីស្នាក់ការជាចម្បង និង ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គលនោះ ។

ច-ប្រសិនបើអ្នកទាមទារជាអ្នកទទួលបន្តសិទ្ធិ (ប្រតិសិទ្ធិ) របស់អ្នកផ្ញើ ឬ អ្នកមានសិទ្ធិទទួលពីការផ្ញើ ត្រូវសរសេរបញ្ជាក់អំពីការណ៍នោះ ។

ឆ-ប្រសិនបើអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិជាអ្នកទាមទារឱ្យប្រគល់ គឺ ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងនោះ ។

ជ-ឈ្មោះតុលាការដែលត្រូវបានទាមទារឱ្យប្រគល់ ។

ឈ-ថ្ងៃ ខែ ឆ្នាំ ទាមទារឱ្យប្រគល់ ។

**ប្រការ ១៦**.- ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងលិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើជាអាទិ៍

១-អ្នកដែលទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ត្រូវភ្ជាប់ជាមួយលិខិតទាមទារឱ្យប្រគល់ នូវឯកសារដែលបញ្ជាក់ថា ខ្លួនមានសិទ្ធិទាមទារឱ្យប្រគល់ឱ្យ ឬ ប្រគល់វិញនូវវត្ថុផ្ញើ ។ ក្នុងករណីនេះ អ្នកដែលទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ត្រូវបង្ហាញលិខិតផ្លូវការដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់សាមីខ្លួនដែលមានបិទរូបថត និង ត្រូវភ្ជាប់ឯកសារចម្លងនៃលិខិតនោះជាមួយលិខិតទាមទារឱ្យប្រគល់ ។

២-ប្រសិនបើនីតិបុគ្គលទាមទារឱ្យប្រគល់ នីតិបុគ្គលនោះត្រូវភ្ជាប់ជាមួយនឹង

លិខិតទាមទារឱ្យប្រគល់ នូវលិខិតបញ្ជាក់លក្ខណសម្បត្តិរបស់អ្នកតំណាងរបស់នីតិបុគ្គលនោះដែលត្រូវបានធ្វើឡើងក្នុងអំឡុងពេល ៣ ខែ គិតមកត្រឹមថ្ងៃទាមទារឱ្យប្រគល់ ។ ក្នុងករណីនេះ អ្នកតំណាងរបស់នីតិបុគ្គលនោះ ត្រូវបង្ហាញលិខិតផ្លូវការដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់ខ្លួនដែលមានបិទរូបថត និង ត្រូវភ្ជាប់ឯកសារចម្លងនៃលិខិតនោះជាមួយលិខិតទាមទារឱ្យប្រគល់ ។

៣-ប្រសិនបើការទាមទារឱ្យប្រគល់ ត្រូវបានធ្វើឡើងដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ អ្នកតំណាងនោះត្រូវភ្ជាប់ជាមួយនឹងលិខិតទាមទារឱ្យប្រគល់ នូវលិខិតបញ្ជាក់សិទ្ធិអំណាចរបស់អ្នកតំណាងនោះ ។ ក្នុងករណីនេះ អ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិនោះត្រូវបង្ហាញលិខិតផ្លូវការដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់អ្នកតំណាងដែលមានបិទរូបថត និង លិខិតផ្លូវការដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់ម្ចាស់សិទ្ធិ និង ត្រូវភ្ជាប់ឯកសារចម្លងនៃលិខិតទាំងពីរនោះជាមួយលិខិតទាមទារឱ្យប្រគល់ ។

**ប្រការ ១៧**.- ការអនុញ្ញាតឱ្យប្រគល់នូវវត្ថុផ្ញើ

ប្រសិនបើយល់ឃើញថា ការទាមទារឱ្យប្រគល់នូវវត្ថុផ្ញើមានមូលហេតុត្រឹមត្រូវ ក្រឡាបញ្ជីត្រូវសរសេរអំពីការណ៍ដែលអនុញ្ញាតឱ្យប្រគល់ នៅលើលិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ត្រូវចុះហត្ថលេខាលើលិខិតនោះ ត្រូវប្រគល់វត្ថុផ្ញើទៅអ្នកទាមទារ ហើយត្រូវឱ្យអ្នកទាមទារបញ្ជាក់ពីការបានទទួលវត្ថុផ្ញើនោះ ។

**ប្រការ ១៨**.- ការសរសេរនៅក្នុងលិខិតពាក្យសុំសម្រាប់តុលាការ ក្នុងករណីដែលប្រគល់នូវវត្ថុផ្ញើ

ក្នុងករណីដែលប្រគល់នូវវត្ថុផ្ញើ ក្រឡាបញ្ជីត្រូវសរសេរនៅក្នុងលិខិតពាក្យសុំសម្រាប់តុលាការ នូវថ្ងៃ ខែ ឆ្នាំ ប្រគល់ ប្រភេទនៃការប្រគល់ (ជាការប្រគល់ឱ្យ ឬ ជាការប្រគល់វិញ) ចំនួនប្រគល់ និង ចំនួនសេសសល់ ។ ប៉ុន្តែ ក្នុងករណីដែលប្រគល់នូវវត្ថុផ្ញើទាំងស្រុង ក្រឡាបញ្ជីអាចសរសេរនូវការណ៍ដែលប្រគល់ឱ្យ ឬ ប្រគល់

វិញនូវវត្ថុផ្ញើទាំងស្រុង ជំនួសថ្ងៃ ខែ ឆ្នាំ ប្រគល់ ប្រភេទនៃការប្រគល់ (ជាការប្រគល់ឱ្យ ឬ ការប្រគល់វិញ) ចំនួនប្រគល់ និង ចំនួនសេសសល់បាន ។

**ប្រការ ១៩.**- ការលើកចោលនូវការទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ

ប្រសិនបើយល់ឃើញថា ការទាមទារឱ្យប្រគល់ពុំមានមូលហេតុត្រឹមត្រូវ ក្រឡាបញ្ជីត្រូវធ្វើលិខិតលើកចោលការទាមទារនោះ ហើយប្រគល់លិខិតនោះឱ្យអ្នកទាមទារ ។

## ជំពូកទី ៤
## បញ្ញត្តិផ្សេងៗ

**ប្រការ ២០.**- ការមើលឯកសារដែលទាក់ទងនឹងការផ្ញើ

១-ជនដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងការផ្ញើ អាចទាមទារមើលឯកសារដែលទាក់ទងនឹងការផ្ញើនោះបាន ។

២-ជនដែលមានបំណងទាមទារមើលឯកសារ ត្រូវដាក់លិខិតពាក្យសុំ តាមទម្រង់លេខ ១៥ នៃឧបសម្ព័ន្ធ ។

**ប្រការ ២១.**- ការបញ្ជាក់អំពីចំណុចដែលទាក់ទងនឹងការផ្ញើ

១-ជនដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងការផ្ញើ អាចទាមទារឱ្យធ្វើការបញ្ជាក់អំពីចំណុចដែលទាក់ទងនឹងការផ្ញើនោះបាន ។

២-ជនដែលមានបំណងទាមទារឱ្យធ្វើការបញ្ជាក់ ត្រូវដាក់លិខិតពាក្យសុំ តាមទម្រង់លេខ ១៦ នៃឧបសម្ព័ន្ធ ។

## ជំពូកទី ៥
## អវសានបញ្ញត្តិ

**ប្រការ ២២.**- កាលបរិច្ឆេទនៃការអនុវត្ត

ប្រកាសនេះត្រូវអនុវត្ត ១ (មួយ) ខែ ក្រោយពេលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ចុះហត្ថលេខាលើប្រកាសនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែ ៦ ឆ្នាំ ២០០៩

**រដ្ឋមន្ត្រី**

អង្គ វង្សវឌ្ឍនា

**ចម្លងជូន :**

- តុលាការខេត្ត-ក្រុង

"ដើម្បីអនុវត្ត"

- តុលាការកំពូល និង មហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍ និង មហាអយ្យការអមសាលាឧទ្ធរណ៍
- អយ្យការអមតុលាការខេត្ត-ក្រុង
- តុលាការយោធា និង អយ្យការអមតុលាការយោធា
- អគ្គាធិការដ្ឋានកិច្ចការតុលាការ
- នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី
- គណៈមេធាវី

"ដើម្បីជ្រាប"

- ឯកសារ-កាលប្បវត្តិ

# មាតិកា


ជំពូកទី ១ បទប្បញ្ញត្តិទូទៅ . . . . . ២

ប្រការ ១.- គោលបំណង . . . . . ២

ប្រការ ២.- មន្ត្រីទទួលបន្ទុកកិច្ចការផ្ញើ . . . . . ២

ប្រការ ៣.- ការចាត់ចែងរបស់ក្រឡាបញ្ជីចំពោះកិច្ចការផ្ញើ . . . . . ២

ប្រការ ៤.- សមត្ថកិច្ចលើការផ្ញើសម្រាប់ជាប្រាតិភោគលើបណ្ដឹង . . . . . ៣

ប្រការ ៥.- ការប្រគល់នូវច្បាប់ដើមនៃឯកសារភ្ជាប់ . . . . . ៣

ជំពូកទី ២ នីតិវិធីផ្ញើវត្ថុដែលជាកម្មវត្ថុនៃការផ្ញើ . . . . . ៣

ប្រការ ៦.- ពាក្យសុំផ្ញើ . . . . . ៣

ប្រការ ៧.- ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងពាក្យសុំផ្ញើ . . . . . ៥

ប្រការ ៨.- ការផ្ញើឧបករណ៍អាចជួញដូរបានដែលមានកំណត់ឈ្មោះ . . . . . ៥

ប្រការ ៩.- ការផ្ញើដើម្បីការប្ដូរប្រាតិភោគ . . . . . ៥

ប្រការ ១០.- នីតិវិធីទទួលពាក្យសុំផ្ញើ . . . . . ៦

ប្រការ ១១.- បញ្ញត្តិពិសេសអំពីការទទួលប្រាក់ផ្ញើ . . . . . ៦

ប្រការ ១២.- ការលើកចោលនូវពាក្យសុំផ្ញើ . . . . . ៧

ជំពូកទី ៣ នីតិវិធីប្រគល់នូវវត្ថុផ្ញើ . . . . . ៨

ប្រការ ១៣.- ការប្រគល់ឱ្យនូវវត្ថុផ្ញើ . . . . . ៨

ប្រការ ១៤.- ការប្រគល់វិញនូវវត្ថុផ្ញើ . . . . . ៨

ប្រការ ១៥.- ការទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ . . . . . ៨

ប្រការ ១៦.- ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងលិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ជាអាទិ៍ . ៩

ប្រការ ១៧.- ការអនុញ្ញាតឱ្យប្រគល់នូវវត្ថុផ្ញើ . . . . . ១០

ប្រការ ១៨.- ការសរសេរនៅក្នុងលិខិតពាក្យសុំសម្រាប់តុលាការ ក្នុងករណីដែលប្រគល់នូវវត្ថុផ្ញើ . . . . . ១០

ប្រការ ១៩.- ការលើកចោលនូវការទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ . . . . . ១១

ជំពូកទី ៤ បញ្ញត្តិផ្សេងៗ . . . . . ១១

ប្រការ ២០.- ការមើលឯកសារដែលទាក់ទងនឹងការផ្ញើ . . . . . ១១

ប្រការ ២១.- ការបញ្ជាក់អំពីចំណុចដែលទាក់ទងនឹងការផ្ញើ . . . . . ១១

ជំពូកទី ៥ អវសានប្បញ្ញត្តិ . . . . . ១១

ប្រការ ២២.- កាលបរិច្ឆេទនៃការអនុវត្ត . . . . . ១១

**ឧបសម្ព័ន្ធ**

ទម្រង់លេខ ១: លិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ) (ការផ្ញើប្រាក់ដើម្បីធានាតាមផ្លូវតុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្ដោះអាសន្ន)

ទម្រង់លេខ ២: លិខិតពាក្យសុំផ្ញើ (សម្រាប់តុលាការ) (ការផ្ញើប្រាក់ដើម្បីធានាតាមផ្លូវតុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្ដោះអាសន្ន)

ទម្រង់លេខ ៣ : លិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ) (ការផ្ញើឧបករណ៍អាចជួញដូរបានដើម្បីធានាតាមផ្លូវតុលាការ )

ទម្រង់លេខ ៤ : លិខិតពាក្យសុំផ្ញើ (សម្រាប់តុលាការ) (ការផ្ញើឧបករណ៍អាចជួញដូរបានដើម្បីធានាតាមផ្លូវតុលាការ)

ទម្រង់លេខ ៥ : លិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ) (ការផ្ញើប្រាក់ដើម្បីគោលបំណងផ្សេងទៀត)

ទម្រង់លេខ ៦ : លិខិតពាក្យសុំផ្ញើ (សម្រាប់តុលាការ) (ការផ្ញើប្រាក់ដើម្បីគោលបំណងផ្សេងទៀត)

ទម្រង់លេខ ៧ : លិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ) (ការផ្ញើប្រាក់ដើម្បីធានាតាមផ្លូវតុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្ដោះអាសន្ន) (ការបង់តាមវិធីផ្ទេរប្រាក់)

ទម្រង់លេខ ៨ : លិខិតពាក្យសុំផ្ញើ (សម្រាប់តុលាការ) (ការផ្ញើប្រាក់ ដើម្បីធានាតាមផ្លូវ តុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្ដោះអាសន្ន) (ការបង់តាមវិធីផ្ទេរប្រាក់)

ទម្រង់លេខ ៩ : លិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ) (ការផ្ញើប្រាក់ដើម្បីគោលបំណងផ្សេងទៀត) (ការបង់តាមវិធីផ្ទេរប្រាក់)

ទម្រង់លេខ ១០ : លិខិតពាក្យសុំផ្ញើ (សម្រាប់តុលាការ) (ការផ្ញើប្រាក់ដើម្បីគោលបំណងផ្សេងទៀត) (ការបង់តាមវិធីផ្ទេរប្រាក់)

ទម្រង់លេខ ១១ : លិខិតជូនដំណឹងអំពីការសម្រេចទទួលការផ្ញើ

ទម្រង់លេខ ១២ : លិខិតស្នើសុំផ្ទេរប្រាក់

ទម្រង់លេខ ១៣ : លិខិតទាមទារឱ្យប្រគល់នូវប្រាក់ផ្ញើ

ទម្រង់លេខ ១៤ : លិខិតទាមទារឱ្យប្រគល់នូវឧបករណ៍អាចជួញដូរបានដែលបានផ្ញើ (ការផ្ញើឧបករណ៍អាចជួញដូរបានដើម្បីធានាតាមផ្លូវតុលាការ)

ទម្រង់លេខ ១៥ : លិខិតពាក្យសុំឱ្យមើលឯកសារ

ទម្រង់លេខ ១៦ : លិខិតពាក្យសុំឱ្យធ្វើការបញ្ជាក់

ទម្រង់លេខ ១ (ទាក់ទងនឹងប្រការ ៦ កថាខណ្ឌទី ១)

# លិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ)

## (ការផ្ញើប្រាក់ដើម្បីធានាតាមផ្លូវតុលាការ និង ដើម្បីដោះពីការរឹបអូសជាបណ្ដោះអាសន្ន)

អ្នកផ្ញើត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

| | |
|---|---|
| ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ខែ ឆ្នាំ | លេខផ្ញើ : ឆ្នាំ |
| ឈ្មោះតុលាការដែលត្រូវបានដាក់ពាក្យសុំផ្ញើ : | ឈ្មោះតុលាការដែលចាត់ការនីតិវិធីនៃការសម្រេចសេចក្ដីដែលពាក់ព័ន្ធនឹងការផ្ញើ និង លេខសំណុំរឿង ជាអាទិ៍<br>តុលាការ :<br>សំណុំរឿងលេខ :<br>ភាគី : |
| ឈ្មោះ ឬ នាមករណ៍របស់អ្នកផ្ញើ :<br>ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :<br>ភេទ :<br>ថ្ងៃខែឆ្នាំកំណើត :<br>អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :<br>ហត្ថលេខា ឬ ស្នាមម្រាមដៃ[១] :<br>(ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :<br>(អាសយដ្ឋាន) :<br>(ហត្ថលេខា ឬ ស្នាមម្រាមដៃ) : | អង្គហេតុដែលជាមូលហេតុនៃការផ្ញើ<br>□ ១. ប្រាតិភោគសម្រាប់ប្រាក់ប្រដាប់ក្ដី<br>□ ២. ប្រាតិភោគសម្រាប់ការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន<br>□ ៣. ប្រាតិភោគដើម្បីឱ្យរួចផុតពីការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន<br>□ ៤. ប្រាតិភោគសម្រាប់ការផ្អាកការអនុវត្តដោយបង្ខំ<br>□ ៥. ប្រាតិភោគសម្រាប់ការលុបចោលនូវការអនុវត្តដោយបង្ខំ<br>□ ៦. ប្រាតិភោគសម្រាប់ការរឹបអូសជាបណ្ដោះអាសន្ន<br>□ ៧. ប្រាតិភោគសម្រាប់ការចាត់ចែងជាបណ្ដោះអាសន្ន<br>□ ៨. ប្រាតិភោគសម្រាប់ការលុបចោលនូវការរឹបអូសជាបណ្ដោះអាសន្ន .<br>□ ៩. ប្រាតិភោគសម្រាប់ការលុបចោលនូវការចាត់ចែងជាបណ្ដោះអាសន្ន<br>□១០. ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន<br>□១១. ( )<br>(សូមគូស □នៅមុខលេខសមស្រប) |
| ឈ្មោះអ្នកមានសិទ្ធិទទួលពីការផ្ញើ :<br>ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :<br>អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង : | |
| បញ្ញត្តិច្បាប់ដែលជាមូលដ្ឋាន :<br>__________ នៃក្រមនីតិវិធីរដ្ឋប្បវេណី | ផ្សេងៗ |
| ទឹកប្រាក់ផ្ញើ (ឯកតា : រៀល)<br>(ហាមកែ ឬ កោសលុប) | |
| សរសេរជាអក្សរ | |

បានទទួលការផ្ញើដូចខាងលើនេះ ។

បានទទួលប្រាក់ផ្ញើដូចខាងលើនេះ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ :

ក្រឡាបញ្ជី :

(កំណត់)

១ ក្នុងករណីដែលធ្វើការផ្ញើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សិទ្ធិទេ ។

ទម្រង់លេខ ២ (ទាក់ទងនឹងប្រការ ៦ កថាខណ្ឌទី ១)

# លិខិតពាក្យសុំផ្ញើ (សម្រាប់តុលាការ)

## (ការផ្ញើប្រាក់ដើម្បីធានាតាមផ្លូវតុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្ដោះអាសន្ន)

អ្នកផ្ញើត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ខែ ឆ្នាំ

លេខផ្ញើ : ឆ្នាំ

ឈ្មោះតុលាការដែលត្រូវបានដាក់ពាក្យសុំផ្ញើ :

ឈ្មោះតុលាការដែលចាត់ការនីតិវិធីនៃការសម្រេចសេចក្ដីដែលពាក់ព័ន្ធនឹងការផ្ញើ និង លេខសំណុំរឿង ជាអាទិ៍
តុលាការ :
សំណុំរឿងលេខ :
ភាគី :

ឈ្មោះ ឬ នាមករណ៍របស់អ្នកផ្ញើ :
ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :
ភេទ :
ថ្ងៃខែឆ្នាំកំណើត :
អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :
ហត្ថលេខា ឬ ស្នាមម្រាមដៃ[1] :

(ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :

(អាសយដ្ឋាន) :
(ហត្ថលេខា ឬ ស្នាមម្រាមដៃ) :

អង្គហេតុដែលជាមូលហេតុនៃការផ្ញើ
□ ១. ប្រាតិភោគសម្រាប់ប្រាក់ប្រដាប់ក្ដី
□ ២. ប្រាតិភោគសម្រាប់ការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន
□ ៣. ប្រាតិភោគដើម្បីឱ្យរួចផុតពីការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន
□ ៤. ប្រាតិភោគសម្រាប់ការផ្អាកការអនុវត្តដោយបង្ខំ
□ ៥. ប្រាតិភោគសម្រាប់ការលុបចោលនូវការអនុវត្តដោយបង្ខំ
□ ៦. ប្រាតិភោគសម្រាប់ការរឹបអូសជាបណ្ដោះអាសន្ន
□ ៧. ប្រាតិភោគសម្រាប់ការចាត់ចែងជាបណ្ដោះអាសន្ន
□ ៨. ប្រាតិភោគសម្រាបការលុបចោលនូវការរឹបអូសជាបណ្ដោះអាសន្ន
□ ៩. ប្រាតិភោគសម្រាប់ការលុបចោលនូវការចាត់ចែងជាបណ្ដោះអាសន្ន
□១០. ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន
□១១. ( )

(សូមគូស □នៅមុខលេខសមស្រប)

ឈ្មោះអ្នកមានសិទ្ធិទទួលពីការផ្ញើ :
ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :
អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :

បញ្ញត្តិច្បាប់ដែលជាមូលដ្ឋាន :
______________________ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ផ្សេងៗ

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ទឹកប្រាក់ផ្ញើ (ឯកតា : រៀល)<br>(ហាមកែ ឬ កោសលុប) | | | | | | | | | | | | | |
| សរសេរជាអក្សរ | | | | | | | | | | | | | |

បានទទួលពាក្យសុំផ្ញើដូចខាងលើនេះ ហើយបានទទួលប្រាក់ផ្ញើដូចខាងលើនេះ ។

ថ្ងៃទី ខែ ឆ្នាំ
តុលាការ :
ក្រឡាបញ្ជី :

| ថ្ងៃ ខែ ឆ្នាំ | ចំនួនប្រគល់ | ចំនួនសេសសល់ | ផ្សេងៗ |
|---|---|---|---|
| | | | |
| | | | |
| | | | |

(កំណត់)

១ ក្នុងករណីដែលធ្វើការផ្ញើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សិទ្ធិទេ ។

ទម្រង់លេខ ៣ (ទាក់ទងនឹងប្រការ ៦ កថាខណ្ឌទី ១)

# លិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ)

## (ការផ្ញើឧបករណ៍អាចជួញដូរបានដើម្បីធានានាមផ្លូវតុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្ដោះអាសន្ន)

អ្នកផ្ញើត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ខែ ឆ្នាំ

លេខផ្ញើ : ឆ្នាំ

ឈ្មោះតុលាការដែលត្រូវបានដាក់ពាក្យសុំផ្ញើ :

ឈ្មោះតុលាការដែលចាត់ការនីតិវិធីនៃការសម្រេចសេចក្ដីដែលពាក់ព័ន្ធនឹងការផ្ញើ និង លេខសំណុំរឿង ជាអាទិ៍

តុលាការ :

សំណុំរឿងលេខ :

ភាគី :

ឈ្មោះ ឬ នាមករណ៍របស់អ្នកផ្ញើ :

ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :

ភេទ :

ថ្ងៃខែឆ្នាំកំណើត :

អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :

ហត្ថលេខា ឬ ស្នាមម្រាមដៃ[1] :

(ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :

(អាសយដ្ឋាន) :

(ហត្ថលេខា ឬ ស្នាមម្រាមដៃ) :

ឈ្មោះអ្នកមានសិទ្ធិទទួលពីការផ្ញើ :

ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :

អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :

អង្គហេតុដែលជាមូលហេតុនៃការផ្ញើ

□ ១. ប្រាតិភោគសម្រាប់ប្រាក់ប្រដាប់ក្ដី

□ ២. ប្រាតិភោគសម្រាប់ការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន

□ ៣. ប្រាតិភោគដើម្បីឱ្យរួចផុតពីការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន

□ ៤. ប្រាតិភោគសម្រាប់ការផ្អាកការអនុវត្តដោយបង្ខំ

□ ៥. ប្រាតិភោគសម្រាប់ការលុបចោលនូវការអនុវត្តដោយបង្ខំ

□ ៦. ប្រាតិភោគសម្រាប់ការរឹបអូសជាបណ្ដោះអាសន្ន

□ ៧. ប្រាតិភោគសម្រាប់ការចាត់ចែងជាបណ្ដោះអាសន្ន

□ ៨. ប្រាតិភោគសម្រាប់ការលុបចោលនូវការរឹបអូសជាបណ្ដោះអាសន្ន

□ ៩. ប្រាតិភោគសម្រាប់ការលុបចោលនូវការចាត់ចែងជាបណ្ដោះអាសន្ន

□១០. ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន

□១១. ( )

(សូមគូស □នៅមុខលេខសមស្រប)

បញ្ញត្តិច្បាប់ដែលជាមូលដ្ឋាន :

____________________ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ផ្សេងៗ

**ឧបករណ៍អាចជួញដូរបានដែលត្រូវបានផ្ញើ**

| ឈ្មោះ | សន្លឹក | ទឹកប្រាក់សរុប | ទឹកប្រាក់មួយសន្លឹក<br>លេខស៊េរី និង លេខរៀង | ផ្សេងៗ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |

បានទទួលការផ្ញើដូចខាងលើនេះ ។

បានទទួលឧបករណ៍អាចជួញដូរបានដែលត្រូវបានផ្ញើដូចខាងលើនេះ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ :

ក្រឡាបញ្ជី :

(កំណត់)

១ ក្នុងករណីដែលធ្វើការផ្ញើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សិទ្ធិទេ ។

ទម្រង់លេខ ៤ ( ទាក់ទងនឹងប្រការ ៦ កថាខណ្ឌទី ១)

# លិខិតពាក្យសុំផ្ញើ (សម្រាប់តុលាការ)

## (ការផ្ញើឧបករណ៍អាចជួញដូរបានដើម្បីធានាតាមផ្លូវតុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្ដោះអាសន្ន)

អ្នកផ្ញើត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ខែ ឆ្នាំ

លេខផ្ញើ : ឆ្នាំ

ឈ្មោះតុលាការដែលត្រូវបានដាក់ពាក្យសុំផ្ញើ :

ឈ្មោះតុលាការដែលចាត់ការនីតិវិធីនៃការសម្រេចសេចក្ដីដែលពាក់ព័ន្ធនឹងការផ្ញើ និង លេខសំណុំរឿង ជាអាទិ៍
តុលាការ :
សំណុំរឿងលេខ :
ភាគី :

ឈ្មោះ ឬ នាមករណ៍របស់អ្នកផ្ញើ :
ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :
ភេទ :
ថ្ងៃខែឆ្នាំកំណើត :
អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :
ហត្ថលេខា ឬ ស្នាមម្រាមដៃ[1] :

( ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :

( អាសយដ្ឋាន) :
( ហត្ថលេខា ឬ ស្នាមម្រាមដៃ) :

អង្គហេតុដែលជាមូលហេតុនៃការផ្ញើ
□ ១. ប្រាតិភោគសម្រាប់ប្រាក់ប្រដាប់ក្ដី
□ ២. ប្រាតិភោគសម្រាប់ការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន
□ ៣.ប្រាតិភោគដើម្បីឱ្យរួចផុតពីការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន
□ ៤. ប្រាតិភោគសម្រាប់ការផ្អាកការអនុវត្តដោយបង្ខំ
□ ៥. ប្រាតិភោគសម្រាប់ការលុបចោលនូវការអនុវត្តដោយបង្ខំ
□ ៦. ប្រាតិភោគសម្រាប់ការរឹបអូសជាបណ្ដោះអាសន្ន
□ ៧. ប្រាតិភោគសម្រាប់ការចាត់ចែងជាបណ្ដោះអាសន្ន
□ ៨. ប្រាតិភោគសម្រាប់ការលុបចោលនូវការរឹបអូសជាបណ្ដោះអាសន្ន
□ ៩. ប្រាតិភោគសម្រាប់ការលុបចោលនូវការចាត់ចែងជាបណ្ដោះអាសន្ន
□១០. ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន
□១១. ( )

( សូមគូស □នៅមុខលេខសមស្រប)

ឈ្មោះអ្នកមានសិទ្ធិទទួលពីការផ្ញើ :
ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :
អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :

បញ្ញត្តិច្បាប់ដែលជាមូលដ្ឋាន :
______________________ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ផ្សេងៗ

ឧបករណ៍អាចជួញដូរបានដែលត្រូវបានផ្ញើ

| ឈ្មោះ | សន្លឹក | ទឹកប្រាក់សរុប | ទឹកប្រាក់មួយសន្លឹក<br>លេខស៊េរី និង លេខរៀង | ផ្សេងៗ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |

បានទទួលការផ្ញើដូចខាងលើនេះ ហើយបានទទួលឧបករណ៍អាចជួញដូរបានដែលត្រូវបានផ្ញើដូចខាងលើនេះ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ :

ក្រឡាបញ្ជី :

| ថ្ងៃ ខែ ឆ្នាំ | ចំនួនសន្លឹក និង ទឹកប្រាក់សរុប ដែលប្រគល់ | ចំនួនសន្លឹក និង ទឹកប្រាក់សរុប ដែលនៅសល់ | ផ្សេងៗ |
|---|---|---|---|
| | | | |
| | | | |
| | | | |

( កំណត់)

១ ក្នុងករណីដែលធ្វើការផ្ញើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សិទ្ធិទេ ។

ទម្រង់លេខ ៥ ( ទាក់ទងនឹងប្រការ ៦ កថាខណ្ឌទី ១)

# លិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ)
# (ការផ្ញើប្រាក់ដើម្បីគោលបំណងផ្សេងទៀត)

អ្នកផ្ញើត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

<table>
<tr><td>ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ខែ ឆ្នាំ</td><td>លេខផ្ញើ : ឆ្នាំ</td></tr>
<tr><td>ឈ្មោះតុលាការដែលត្រូវបានដាក់ពាក្យសុំផ្ញើ :</td><td rowspan="3">អង្គហេតុដែលជាមូលហេតុនៃការផ្ញើ</td></tr>
<tr><td>ឈ្មោះ ឬ នាមករណ៍របស់អ្នកផ្ញើ :<br>ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :<br>ភេទ :<br>ថ្ងៃខែឆ្នាំកំណើត :<br>អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :<br>ហត្ថលេខា ឬ ស្នាមម្រាមដៃ[1] :<br><br>(ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :<br><br>(អាសយដ្ឋាន) :<br>(ហត្ថលេខា ឬ ស្នាមម្រាមដៃ) :</td></tr>
<tr><td>ឈ្មោះអ្នកមានសិទ្ធិទទួលពីការផ្ញើ :<br>ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :<br>អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :</td></tr>
<tr><td>បញ្ញត្តិច្បាប់ដែលជាមូលដ្ឋាន :<br>____________________ នៃក្រមនីតិវិធីរដ្ឋប្បវេណី</td><td>ផ្សេងៗ</td></tr>
<tr><td>ទឹកប្រាក់ផ្ញើ ( ឯកតា : រៀល)<br>(បោមតែ ឬ កោសលុប)</td><td></td></tr>
<tr><td>សរសេរជាអក្សរ</td><td></td></tr>
</table>

បានទទួលការផ្ញើដូចខាងលើនេះ ។

បានទទួលប្រាក់ផ្ញើដូចខាងលើនេះ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ :

ក្រឡាបញ្ជី :

( កំណត់)

១ ក្នុងករណីដែលធ្វើការផ្ញើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សិទ្ធិទេ ។

ទម្រង់លេខ ៦ ( ទាក់ទងនឹងប្រការ ៦ កថាខណ្ឌទី ១)

# លិខិតពាក្យសុំផ្ញើ (សម្រាប់តុលាការ)

# (ការផ្ញើប្រាក់ដើម្បីគោលបំណងផ្សេងទៀត)

អ្នកដាក់បញ្ញើត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

| | |
|---|---|
| ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ខែ ឆ្នាំ | លេខផ្ញើ : ឆ្នាំ |
| ឈ្មោះតុលាការដែលត្រូវបានដាក់ពាក្យសុំផ្ញើ : | អង្គហេតុដែលជាមូលហេតុនៃការផ្ញើ |
| ឈ្មោះ ឬ នាមករណ៍របស់អ្នកផ្ញើ :<br>ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :<br>ភេទ :<br>ថ្ងៃខែឆ្នាំកំណើត :<br>អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :<br>ហត្ថលេខា ឬ ស្នាមម្រាមដៃ[១] :<br>(ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :<br>(អាសយដ្ឋាន) :<br>(ហត្ថលេខា ឬ ស្នាមម្រាមដៃ) : | |
| ឈ្មោះអ្នកមានសិទ្ធិទទួលពីការផ្ញើ :<br>ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :<br>អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង : | |
| បញ្ញត្តិច្បាប់ដែលជាមូលដ្ឋាន :<br>______________________ នៃក្រមនីតិវិធីរដ្ឋប្បវេណី | ផ្សេងៗ |
| ទឹកប្រាក់ផ្ញើ ( ឯកតា : រៀល)<br>(ហាមកែ ឬ កោសលុប) | |
| សរសេរជាអក្សរ | |

បានទទួលការផ្ញើដូចខាងលើនេះ ហើយបានទទួលប្រាក់ផ្ញើដូចខាងលើនេះ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ :

ក្រឡាបញ្ជី :

| ថ្ងៃ ខែ ឆ្នាំ | ចំនួនប្រគល់ | ចំនួនសេសសល់ | ផ្សេងៗ |
|---|---|---|---|
| | | | |
| | | | |
| | | | |

( កំណត់)

១ ក្នុងករណីដែលធ្វើការផ្ញើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សិទ្ធិទេ ។

ទម្រង់លេខ ៧ ( ទាក់ទងនឹងប្រការ ១១ កថាខណ្ឌទី ១)

# លិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ)

## (ការផ្ញើប្រាក់ដើម្បីធានាតាមផ្លូវតុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្ដោះអាសន្ន)

## (ការបង់តាមវិធីផ្ទេរប្រាក់)

អ្នកផ្ញើត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

| | |
|---|---|
| ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ខែ ឆ្នាំ | លេខផ្ញើ : ឆ្នាំ |
| ឈ្មោះតុលាការដែលត្រូវបានដាក់ពាក្យសុំផ្ញើ : | ឈ្មោះតុលាការដែលចាត់ការនីតិវិធីនៃការសម្រេចសេចក្ដីដែលពាក់ព័ន្ធនឹងការផ្ញើ និង លេខសំណុំរឿង ជាអាទិ៍<br>តុលាការ :<br>សំណុំរឿងលេខ :<br>ភាគី : |
| ឈ្មោះ ឬ នាមករណ៍របស់អ្នកផ្ញើ :<br>ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :<br>ភេទ :<br>ថ្ងៃខែឆ្នាំកំណើត :<br>អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :<br>ហត្ថលេខា ឬ ស្នាមម្រាមដៃ[1] :<br><br>( ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :<br><br>( អាសយដ្ឋាន) :<br>( ហត្ថលេខា ឬ ស្នាមម្រាមដៃ) : | អង្គហេតុដែលជាមូលហេតុនៃការផ្ញើ<br>□ ១.ប្រាតិភោគសម្រាប់ប្រាក់ប្រដាប់ក្ដី<br>□ ២.ប្រាតិភោគសម្រាប់ការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន<br>□ ៣.ប្រាតិភោគដើម្បីឱ្យរួចផុតពីការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន<br>□ ៤. ប្រាតិភោគសម្រាប់ការផ្អាកការអនុវត្តដោយបង្ខំ<br>□ ៥. ប្រាតិភោគសម្រាប់ការលុបចោលនូវការអនុវត្តដោយបង្ខំ<br>□ ៦. ប្រាតិភោគសម្រាប់ការរឹបអូសជាបណ្ដោះអាសន្ន<br>□ ៧. ប្រាតិភោគសម្រាប់ការចាត់ចែងជាបណ្ដោះអាសន្ន<br>□ ៨. ប្រាតិភោគសម្រាប់ការលុបចោលនូវការរឹបអូសជាបណ្ដោះអាសន្ន<br>□ ៩. ប្រាតិភោគសម្រាប់ការលុបចោលនូវការចាត់ចែងជាបណ្ដោះអាសន្ន<br>□១០. ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន<br>□១១. ( )<br>( សូមគូស □នៅមុខលេខសមស្រប) |
| ឈ្មោះអ្នកមានសិទ្ធិទទួលពីការផ្ញើ :<br>ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :<br>អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង : | |
| បញ្ញត្តិច្បាប់ដែលជាមូលដ្ឋាន :<br>____________________នៃក្រមនីតិវិធីរដ្ឋប្បវេណី | ផ្សេង១ |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ទឹកប្រាក់ផ្ញើ ( ឯកតា : រៀល)<br>( ហាមកែ ឬ កោសលុប) | | | | | | | | | | | | | |
| សរសេរជាអក្សរ | | | | | | | | | | | | | |

បានទទួលការផ្ញើដូចខាងលើនេះ ។

សូមផ្ទេរប្រាក់ផ្ញើមកគណនីប្រាក់ផ្ញើរបស់តុលាការនេះ ( ក្រឡាបញ្ជី) រហូតដល់ថ្ងៃទី ____ ខែ _____ ឆ្នាំ _____ ។

ការសម្រេចទទួលការផ្ញើខាងលើនេះ ត្រូវបាត់បង់អានុភាព ប្រសិនបើមិនបានផ្ទេរប្រាក់ផ្ញើរហូត ដល់កាលបរិច្ឆេទខាងលើនេះ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ : ក្រឡាបញ្ជី :

បញ្ជាក់ថា បានទទួលប្រាក់ផ្ញើ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ : ក្រឡាបញ្ជី :

( កំណត់)

១ ក្នុងករណីដែលធ្វើការផ្ញើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សិទ្ធិទេ ។

ទម្រង់លេខ ៨ (ទាក់ទងនឹងប្រការ ១១ កថាខណ្ឌទី ១)

# លិខិតពាក្យសុំផ្ញើ (សម្រាប់តុលាការ)
## (ការផ្ញើប្រាក់ដើម្បីធានាតាមផ្លូវតុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្ដោះអាសន្ន)
## (ការបង់តាមវិធីផ្ទេរប្រាក់)

អ្នកផ្ញើត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

<table>
<tr><td>ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ខែ ឆ្នាំ</td><td>លេខផ្ញើ : ឆ្នាំ</td></tr>
<tr><td>ឈ្មោះតុលាការដែលត្រូវបានដាក់ពាក្យសុំផ្ញើ :<br><br>ឈ្មោះ ឬ នាមករណ៍របស់អ្នកផ្ញើ :<br>ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :<br>ភេទ :<br>ថ្ងៃខែឆ្នាំកំណើត :<br>អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :<br>ហត្ថលេខា ឬ ស្នាមម្រាមដៃ[១] :<br><br>(ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :<br><br>(អាសយដ្ឋាន) :<br>(ហត្ថលេខា ឬ ស្នាមម្រាមដៃ) :</td><td>ឈ្មោះតុលាការដែលចាត់ការនីតិវិធីនៃការសម្រេចសេចក្ដីដែលពាក់ព័ន្ធនឹងការផ្ញើ និង លេខសំណុំរឿង ជាអាទិ៍<br>តុលាការ :<br>សំណុំរឿងលេខ :<br>ភាគី :<br><br>អង្គហេតុដែលជាមូលហេតុនៃការផ្ញើ<br>□ ១.ប្រាតិភោគសម្រាប់ប្រាក់ប្រដាប់ក្ដី<br>□ ២.ប្រាតិភោគសម្រាប់ការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន<br>□ ៣.ប្រាតិភោគដើម្បីឱ្យរួចផុតពីការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន<br>□ ៤. ប្រាតិភោគសម្រាប់ការផ្អាកការអនុវត្តដោយបង្ខំ<br>□ ៥. ប្រាតិភោគសម្រាប់ការលុបចោលនូវការអនុវត្តដោយបង្ខំ<br>□ ៦. ប្រាតិភោគសម្រាប់ការរឹបអូសជាបណ្ដោះអាសន្ន<br>□ ៧. ប្រាតិភោគសម្រាប់ការចាត់ចែងជាបណ្ដោះអាសន្ន<br>□ ៨. ប្រាតិភោគសម្រាប់ការលុបចោលនូវការរឹបអូសជាបណ្ដោះអាសន្ន<br>□ ៩. ប្រាតិភោគសម្រាប់ការលុបចោលនូវការចាត់ចែងជាបណ្ដោះអាសន្ន<br>□១០. ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន<br>□១០. ( )<br><br>(សូមគូស □ នៅមុខលេខសមស្រប)</td></tr>
<tr><td>ឈ្មោះអ្នកមានសិទ្ធិទទួលពីការផ្ញើ :<br>ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :<br>អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :</td><td></td></tr>
<tr><td>បញ្ញត្តិច្បាប់ដែលជាមូលដ្ឋាន :<br>________________ នៃក្រមនីតិវិធីរដ្ឋប្បវេណី</td><td>ផ្សេងៗ</td></tr>
<tr><td>ទឹកប្រាក់ផ្ញើ (ឯកតា : រៀល)<br>(ហាមកែ ឬ កោសលុប)</td><td>| | | | | | | | | | | | |</td></tr>
<tr><td>សរសេរជាអក្សរ</td><td></td></tr>
</table>

បានទទួលពាក្យសុំផ្ញើដូចខាងលើនេះ ។

សូមផ្ទេរប្រាក់ផ្ញើមកគណនីប្រាក់ផ្ញើរបស់តុលាការនេះ (ក្រឡាបញ្ជី) រហូតដល់ថ្ងៃទី ____ ខែ ______ ឆ្នាំ ______ ។

ការសម្រេចទទួលការផ្ញើខាងលើនេះ ត្រូវបាត់បង់អានុភាព ប្រសិនបើមិនបានផ្ទេរប្រាក់ផ្ញើរហូត ដល់កាលបរិច្ឆេទខាងលើនេះ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ : ក្រឡាបញ្ជី :

បានទទួលប្រាក់ផ្ញើ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ : ក្រឡាបញ្ជី :

| ថ្ងៃ ខែ ឆ្នាំ | ចំនួនប្រគល់ | ចំនួនសេសសល់ | ផ្សេងៗ |
|---|---|---|---|
| | | | |
| | | | |
| | | | |

(កំណត់)

១ ក្នុងករណីដែលធ្វើការផ្ញើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សិទ្ធិទេ ។

ទម្រង់លេខ ៩ ( ទាក់ទងនឹងប្រការ ១១ កថាខណ្ឌទី ១)

# លិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ)
## (ការផ្ញើប្រាក់ដើម្បីគោលបំណងផ្សេងទៀត)
## (ការបង់តាមវិធីផ្ទេរប្រាក់)

អ្នកផ្ញើត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

| | |
|---|---|
| ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ខែ ឆ្នាំ | លេខផ្ញើ : ឆ្នាំ |
| ឈ្មោះតុលាការដែលត្រូវបានដាក់ពាក្យសុំផ្ញើ : | អង្គហេតុដែលជាមូលហេតុនៃការផ្ញើ |
| ឈ្មោះ ឬ នាមករណ៍របស់អ្នកផ្ញើ :<br>ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :<br>ភេទ :<br>ថ្ងៃខែឆ្នាំកំណើត :<br>អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :<br>ហត្ថលេខា ឬ ស្នាមម្រាមដៃ[១] :<br><br>( ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :<br><br>( អាសយដ្ឋាន) :<br>( ហត្ថលេខា ឬ ស្នាមម្រាមដៃ) : | |
| ឈ្មោះអ្នកមានសិទ្ធិទទួលពីការផ្ញើ :<br>ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :<br>អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង : | |
| បញ្ញត្តិច្បាប់ដែលជាមូលដ្ឋាន :<br>________________ នៃក្រមនីតិវិធីរដ្ឋប្បវេណី | ផ្សេងៗ |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ទឹកប្រាក់ផ្ញើ ( ឯកតា : រៀល)<br>( ហាមកែ ឬ កោសលុប) | | | | | | | | | | | | | |
| សរសេរជាអក្សរ | | | | | | | | | | | | | |

បានទទួលការផ្ញើដូចខាងលើនេះ ។

សូមផ្ទេរប្រាក់ផ្ញើមកគណនីប្រាក់ផ្ញើរបស់តុលាការនេះ ( ក្រឡាបញ្ជី) រហូតដល់ថ្ងៃទី ____ ខែ ______ ឆ្នាំ _____ ។

ការសម្រេចទទួលការផ្ញើខាងលើនេះ ត្រូវបាត់បង់អានុភាព ប្រសិនបើមិនបានផ្ទេរប្រាក់ផ្ញើរហូត ដល់កាលបរិច្ឆេទខាងលើនេះ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ : ក្រឡាបញ្ជី :

បញ្ជាក់ថា បានទទួលប្រាក់ផ្ញើ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ : ក្រឡាបញ្ជី :

( កំណត់)

១ ក្នុងករណីដែលធ្វើការផ្ញើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សិទ្ធិទេ ។

ទម្រង់លេខ ១០ (ទាក់ទងនឹងប្រការ ១១ កថាខណ្ឌទី ១)

# លិខិតពាក្យសុំផ្ញើ (សម្រាប់តុលាការ)
## (ការផ្ញើប្រាក់ដើម្បីគោលបំណងផ្សេងទៀត)
## (ការបង់តាមវិធីផ្ទេរប្រាក់)

អ្នកដាក់បញ្ញើត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

<table>
<tr><td colspan="5">ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ខែ ឆ្នាំ</td><td colspan="9">លេខផ្ញើ : ឆ្នាំ</td></tr>
<tr><td colspan="5">ឈ្មោះតុលាការដែលត្រូវបានដាក់ពាក្យសុំផ្ញើ :</td><td colspan="9" rowspan="3">អង្គហេតុដែលជាមូលហេតុនៃការផ្ញើ</td></tr>
<tr><td colspan="5">ឈ្មោះ ឬ នាមករណ៍របស់អ្នកផ្ញើ :<br>ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :<br>ភេទ :<br>ថ្ងៃខែឆ្នាំកំណើត :<br>អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :<br>ហត្ថលេខា ឬ ស្នាមម្រាមដៃ[១] :<br><br>(ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :<br><br>(អាសយដ្ឋាន) :<br>(ហត្ថលេខា ឬ ស្នាមម្រាមដៃ) :</td></tr>
<tr><td colspan="5">ឈ្មោះអ្នកមានសិទ្ធិទទួលពីការផ្ញើ :<br>ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :<br>អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :</td></tr>
<tr><td colspan="5">បញ្ញត្តិច្បាប់ដែលជាមូលដ្ឋាន :<br>________________________ នៃក្រមនីតិវិធីរដ្ឋប្បវេណី</td><td colspan="9">ផ្សេងៗ</td></tr>
<tr><td>ទឹកប្រាក់ផ្ញើ (ឯកតា : រៀល)<br>(ហាមកែ ឬ កោសលុប)</td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td>សរសេរជាអក្សរ</td><td colspan="13"></td></tr>
</table>

បានទទួលការផ្ញើដូចខាងលើនេះ ។

សូមផ្ទេរប្រាក់ផ្ញើមកគណនីប្រាក់ផ្ញើរបស់តុលាការនេះ (ក្រឡាបញ្ជី) រហូតដល់ថ្ងៃទី ____ ខែ ______ ឆ្នាំ _____ ។

ការសម្រេចទទួលការផ្ញើខាងលើនេះ ត្រូវបាត់បង់អានុភាព ប្រសិនបើមិនបានផ្ទេរប្រាក់ផ្ញើរហូត ដល់កាលបរិច្ឆេទខាងលើនេះ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ : ក្រឡាបញ្ជី :

បានទទួលប្រាក់ផ្ញើ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ : ក្រឡាបញ្ជី :

| ថ្ងៃ ខែ ឆ្នាំ | ចំនួនប្រគល់ | ចំនួនសេសសល់ | ផ្សេងៗ |
|---|---|---|---|
| | | | |
| | | | |
| | | | |

(កំណត់)

១ ក្នុងករណីដែលធ្វើការផ្ញើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សិទ្ធិទេ ។

ទម្រង់លេខ ១១ ( ទាក់ទងនឹងប្រការ ១១ កថាខណ្ឌទី ៣)

# លិខិតជូនដំណឹងអំពីការសម្រេចទទួលការផ្ញើ

ការផ្ញើដែលអ្នកបានដាក់ពាក្យសុំ នៅថ្ងៃទី ____ ខែ ______ ឆ្នាំ _____ ត្រូវបានទទួលដោយមានលេខ : __________ ឆ្នាំ _______ ។

ចំពោះប្រាក់ផ្ញើ សូមផ្ទេរមកគណនីប្រាក់ផ្ញើដែលបានកំណត់ ដោយយកលិខិតស្នើសុំផ្ទេរប្រាក់ដែលភ្ជាប់ជាមួយលិខិតនេះ រហូតដល់ថ្ងៃទី _____ ខែ ______ ឆ្នាំ _____ ។ ប្រសិនបើពុំមានការផ្ទេរប្រាក់ផ្ញើរហូតដល់កាលបរិច្ឆេទនេះ ការសម្រេចទទួលការផ្ញើនេះ ត្រូវបាត់បង់អានុភាព ។

ចំពោះលិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ) នឹងត្រូវប្រគល់ (ឬ ផ្ញើ) ទៅឱ្យអ្នក ក្រោយពេលទទួលការផ្ទេរប្រាក់ ហេតុដូច្នេះ សូមរក្សាទុកដោយប្រុងប្រយ័ត្ន ។

ថ្ងៃទី ____ ខែ ______ ឆ្នាំ

តុលាការ : ក្រឡាបញ្ជី :

ទម្រង់លេខ ១២ (ទាក់ទងនឹងប្រការ ១១ កថាខណ្ឌទី ៣)



# លិខិតស្នើសុំផ្ទេរប្រាក់

| | | | | |
|---|---|---|---|---|
| ថ្ងៃស្នើសុំ | ថ្ងៃទី ខែ ឆ្នាំ | ចំនួនទឹកប្រាក់ផ្ទេរ | | រៀល |
| ស្ថាប័នហិរញ្ញវត្ថុដែលទទួលការផ្ទេរ | | ចំនួនថ្លៃសេវា | | រៀល |
| អ្នកទទួល | ប្រភេទនៃគណនី | ចរន្ត | លេខគណនី | |
| | ឈ្មោះម្ចាស់គណនី | | | |
| លេខផ្ញើ | លេខ : ឆ្នាំ | | | |
| អ្នកស្នើសុំ | អាសយដ្ឋាន | | | |
| | ឈ្មោះ ឬ នាមករណ៍ | | | |
| ត្រាទទួល ឬ ត្រាផ្ទេរ របស់ស្ថាប័នហិរញ្ញវត្ថុដែលធ្វើការផ្ទេរ | | | | |

# បង្កាន់ដៃទទួលប្រាក់ផ្ទេរ និង តម្លៃសេវា

| | | | | |
|---|---|---|---|---|
| ថ្ងៃស្នើសុំ | ថ្ងៃទី ខែ ឆ្នាំ | ចំនួនទឹកប្រាក់ផ្ទេរ | | រៀល |
| ស្ថាប័នហិរញ្ញវត្ថុដែលទទួលការផ្ទេរ | | ចំនួនថ្លៃសេវា | | រៀល |
| អ្នកទទួល | ប្រភេទនៃគណនី | ចរន្ត | លេខគណនី | |
| | ឈ្មោះម្ចាស់គណនី | | | |
| លេខផ្ញើ | លេខ : | ឆ្នាំ | | |
| អ្នកស្នើសុំ | អាសយដ្ឋាន | | | |
| | ឈ្មោះ ឬ នាមករណ៍ | | | |
| ត្រាទទួល របស់ស្ថាប័នហិរញ្ញវត្ថុដែលធ្វើការផ្ទេរ | | | | |

ទម្រង់លេខ ១៣ (ទាក់ទងនឹងប្រការ ១៥ កថាខណ្ឌទី ១)

# លិខិតទាមទារឱ្យប្រគល់នូវប្រាក់ផ្ញើ

## (ការផ្ញើប្រាក់ដើម្បីធានាតាមផ្លូវតុលាការ និង ដើម្បីរំដោះពីការមិនអួសដាយឈ្មោះអាសន្ន)

អ្នកទាមទារត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ខែ ឆ្នាំ

លេខទទួល : ឆ្នាំ

ឈ្មោះតុលាការដែលត្រូវបានទាមទារឱ្យប្រគល់ :

ឈ្មោះ ឬ នាមករណ៍របស់អ្នកទាមទារ :

ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :

ភេទ :

ថ្ងៃខែឆ្នាំកំណើត :

អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :

ហត្ថលេខា ឬ ស្នាមម្រាមដៃ[១] :

(ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :

(អាសយដ្ឋាន) :

(ហត្ថលេខា ឬ ស្នាមម្រាមដៃ) :

មូលហេតុនៃការទាមទារឱ្យប្រគល់
និង ការបញ្ជាក់អំពីការប្រគល់ឱ្យ ឬ ការប្រគល់វិញ

□ការប្រគល់ឱ្យ □១. អនុវត្តសិទ្ធិប្រាតិភោគ
□២. (   )

□ការប្រគល់វិញ □១. ការរលត់នៃមូលហេតុនៃការផ្ញើ
□២. (   )

(សូមគូស □ នៅមុខលេខបញ្ជាក់មូលហេតុដែលសមស្រប ។ ក្រៅពីមូលហេតុ "អនុវត្តសិទ្ធិប្រាតិភោគ" ឬ "ការរលត់នៃមូលហេតុនៃការផ្ញើ" សូមសរសេរបញ្ជាក់អំពីមូលហេតុ នៅក្នុងវង់ក្រចកខាងលើនេះ ។

ផ្សេងៗ

| លេខបញ្ញើ | ចំនួនទឹកប្រាក់បញ្ញើ |
|---|---|
| លេខ ឆ្នាំ | |
| លេខ ឆ្នាំ | |
| លេខ ឆ្នាំ | |
| លេខ ឆ្នាំ | |
| ទឹកប្រាក់សរុប | |

បានយល់ព្រមប្រគល់ដូចមានបញ្ជាក់ខាងលើ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ :

ក្រឡាបញ្ជី :

បានទទួលប្រាក់ដូចដែលមានបញ្ជាក់ខាងលើ ។

ថ្ងៃទី ខែ ឆ្នាំ

ឈ្មោះអ្នកទទួល :

(ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :

(កំណត់)

១ ក្នុងករណីដែលធ្វើការទាមទារដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សិទ្ធិទេ ។

ទម្រង់លេខ ១៤ (ទាក់ទងនឹងប្រការ ១៥ កថាខណ្ឌទី ១)

# លិខិតទាមទារឱ្យប្រគល់នូវឧបករណ៍អាចជួញដូរបានដែលបានផ្ញើ

## (ការផ្ញើឧបករណ៍អាចជួញដូរបានដើម្បីធានាតាមផ្លូវតុលាការ និង ដើម្បីដោះពីការរឹបអូសជាបណ្ដោះអាសន្ន)

អ្នកទាមទារត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ខែ ឆ្នាំ

លេខទទួល : ឆ្នាំ

ឈ្មោះតុលាការដែលត្រូវបានទាមទារឱ្យប្រគល់ :

ឈ្មោះ ឬ នាមករណ៍របស់អ្នកទាមទារ :
ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :
ភេទ :
ថ្ងៃខែឆ្នាំកំណើត :
អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :
ហត្ថលេខា ឬ ស្នាមម្រាមដៃ[1] :

(ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :

(អាសយដ្ឋាន) :
(ហត្ថលេខា ឬ ស្នាមម្រាមដៃ) :

មូលហេតុនៃការទាមទារឱ្យប្រគល់
និង ការបញ្ជាក់អំពីការប្រគល់ឱ្យ ឬ ការប្រគល់វិញ

□ការប្រគល់ឱ្យ □១. អនុវត្តសិទ្ធិប្រាតិភោគ
□២. ( )

□ការប្រគល់វិញ □១. ការរលត់នៃមូលហេតុនៃការផ្ញើ
□២. ( )

(សូមគូស □ នៅមុខលេខបញ្ជាក់មូលហេតុដែលសមស្រប ។ ក្រៅពីមូលហេតុ "អនុវត្តសិទ្ធិប្រាតិភោគ" ឬ "ការរលត់នៃមូលហេតុនៃការផ្ញើ" សូមសរសេរបញ្ជាក់អំពីមូលហេតុ នៅក្នុងវង់ក្រចកខាងលើនេះ ។

ផ្សេងៗ

| លេខបញ្ញើ | ឈ្មោះ | សន្លឹក | ទឹកប្រាក់សរុប | ទឹកប្រាក់មួយសន្លឹក លេខសេរី និង លេខរៀង | ផ្សេងៗ |
|---|---|---|---|---|---|
| លេខ ឆ្នាំ | | | | | |
| លេខ ឆ្នាំ | | | | | |
| លេខ ឆ្នាំ | | | | | |
| លេខ ឆ្នាំ | | | | | |
| សរុប | | | | | |

បានយល់ព្រមប្រគល់ដូចមានបញ្ជាក់ខាងលើ ។
ថ្ងៃទី ខែ ឆ្នាំ
តុលាការ :
ក្រឡាបញ្ជី :

បានទទួលឧបករណ៍អាចជួញដូរបានដែលមានបញ្ជាក់ខាងលើ ។
ថ្ងៃទី ខែ ឆ្នាំ
ឈ្មោះអ្នកទទួល :
(ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :

(កំណត់)

១ ក្នុងករណីដែលធ្វើការទាមទារដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សិទ្ធិទេ ។

# លិខិតពាក្យសុំឱ្យមើលឯកសារ

ជូនចំពោះតុលាការ ____________________________

គោលបំណងនៃការមើល :

(ការពាក់ព័ន្ធនឹងផលប្រយោជន៍)

ឯកសារទាក់ទង និង ផ្នែកនៃឯកសារនោះដែលទាមទារឱ្យមើល :

ខ្ញុំស្នើសុំឱ្យមើលឯកសារ ដូចដែលបានរៀបរាប់ខាងលើ ។

ថ្ងៃទី ខែ ឆ្នាំ

អ្នកដាក់ពាក្យសុំ[១] : □អ្នកផ្ញើ □អ្នកមានសិទ្ធិទទួលពីការផ្ញើ □អ្នកដទៃ

ឈ្មោះ ឬ នាមករណ៍

អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង

១ សូមគូស □ នៅមុខប្រភេទនៃអ្នកដាក់ពាក្យសុំ ។

ទម្រង់លេខ ១៦ (ទាក់ទងនឹងប្រការ ២១ កថាខណ្ឌទី ២)

# លិខិតពាក្យសុំឱ្យធ្វើការបញ្ជាក់

ជូនចំពោះតុលាការ ______________________________

គោលបំណងនៃការទាមទារឱ្យធ្វើការបញ្ជាក់ :
(ការពាក់ព័ន្ធនឹងផលប្រយោជន៍)

ចំណុចដែលទាមទារឱ្យធ្វើការបញ្ជាក់ :

ខ្ញុំស្នើសុំឱ្យធ្វើការបញ្ជាក់ ដូចដែលបានរៀបរាប់ខាងលើ ។

ថ្ងៃទី ខែ ឆ្នាំ

អ្នកដាក់ពាក្យសុំ[១] : □អ្នកធ្វើ □អ្នកមានសិទ្ធិទទួលពីការធ្វើ □អ្នកដទៃ
ឈ្មោះ ឬ នាមករណ៍

អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង

១ សូមគូស □ នៅមុខប្រភេទនៃអ្នកដាក់ពាក្យសុំ ។